ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

*******

សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៦
ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧
សំណុំរឿងស៊ើបសួរលេខ: ១៩៧
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៧
សំណុំរឿងជំនុំជម្រះលេខ: ៦១៥
ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២១
សាលក្រមព្រហ្មទណ្ឌលេខ: ១៦ "ខ"
ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២២

# ត ា ង ន ា ម ប្រ ជ ា រ ា ស្ត្រ ខ្មែរ

## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

-កាលបរិច្ឆេទបើកសវនាការ: ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០២១ វេលាព្រឹក។

-កាលបរិច្ឆេទប្រកាសសាលក្រម: ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០២២ វេលាព្រឹក។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] ពន្លក ភេទប្រុស ឆ្នាំកំណើត១៩៩៤ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ។ ទីកន្លែងកំណើតនៅភូមិសំ[redacted] ខេត្តតាកែវ។ ទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] ចន្លន (រ) ម្តាយឈ្មោះ [redacted] មីនា (រ) នៅលីវ ទោសពីមុន គ្មាន។

ជាប់ចោទពីបទ: **បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ និងទោស ដែលមានចែងក្នុងមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-តាមដីកាដំណោះស្រាយលេខ:១៩៣២ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ស្ពឺ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

**ជនរងគ្រោះ**

ឈ្មោះ [redacted] ឡាយហេង ភេទស្រី ឆ្នាំកំណើត១៩៩៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ។ ទីលំនៅបច្ចុប្បន្នភូមិព្នៅ ឃុំព្រៃញាតិ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

**ឯអង្គហេតុកើតមានឡើងដូចតទៅ:** កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ១៨ និង ៥៥នាទី ស្ថិតនៅភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានករណី បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ មួយបានកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] ពន្លក បានបើកបរម៉ូតូមួយគ្រឿងម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ចេញពីការ៉ាស់សាំងគេលាវ្វចបត់ទៅទិសខាងជើង លុះដល់ចំណុចខាងលើបានបុកម៉ូតូមួយគ្រឿងម៉ាកហុងដាសេ៥០ ពណ៌ស្លៃ បើកបរដោយឈ្មោះ [redacted] ឡាយហេង ដែលកំពុងតែបើកបរពីទិសខាងជើងទៅខាងត្បូងបណ្តាលឲ្យគ្រោះថ្នាក់មនុស្សពីនាក់ និងខូចខាតម៉ូតូចំនួន ០២គ្រឿង ប្រាកដមែន។



Scanned with CamScanner

## នាពេលសវនាការ

**ក្រោយពីបាន:**

- ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ពន្លក
- ស្តាប់ចម្លើយជនរងគ្រោះឈ្មោះ [redacted] ឡាយហេង
- ស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ និងកំណត់ហេតុផ្សេងៗទៀត
- ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ស្តាប់ជនជាប់ចោទសំណូមពរផ្សេងៗ
- ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.តាមការពិនិត្យកំណត់ហេតុគ្រូតពិនិត្យកន្លែងកើតហេតុ គំនូសស្នាមនៃគ្រោះថ្នាក់ចរាចរណ៍ និងតាមការពិនិត្យភស្តុតាងមួយចំនួនឃើញថា: ពិតជាមានអំពើ បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ កើតឡើងកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ១៨ និង ៥៥នាទី នៅលើផ្លូវជាតិលេខ ៥១ ចន្លោះគីឡូម៉ែត្រលេខ ១៦-១៧ ត្រង់ចំណុចភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានម៉ូតូមួយគ្រឿងម៉ាក ហុងដាC125 ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CX-9611 អ្នកបើកបរឈ្មោះ [redacted] ពន្លក ភេទប្រុស អាយុ ២៣ឆ្នាំ បើកបរចេញពីកាព៉ស់សាំងតេលាពីទិសខាងលិចរួចបត់ទៅទិសខាងជើង លុះដល់ត្រង់ចំណុចខាងលើបានទៅបុកម៉ូតូ ០១គ្រឿងម៉ាកហុងដាC50 ពណ៌ស្លែ ពាក់ផ្លាកលេខភ្នំពេញ 1H-5309 បើកបរដោយឈ្មោះ [redacted] ឡាយហេង ភេទស្រី អាយុ ៣៣ឆ្នាំ ដែលកំពុងតែបើកបរពីទិសខាងជើង ទៅទិសខាងត្បូង បណ្តាលឲ្យគ្រោះថ្នាក់មនុស្ស និងខូចខាតម៉ូតូចំនួន ០២គ្រឿង។

តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពន្លក បានបញ្ជាក់ថា: នៅថ្ងៃទី១៤-១២-២០១៦ វេលាម៉ោង ១៨ បានជិះម៉ូតូចេញពីរោងចក្រខាងកើតភ្នំស្រង់សំដៅទៅផ្ទះ នៅខេត្តតាកែវ ដោយបើកបរម៉ូតូទិសដៅពីត្បូងទៅជើង ធ្វើដំណើរដល់ភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានភ្លៀងធ្លាក់ បានស៊ីញ៉ូឆ្លងផ្លូវពីកើត ទៅលិចរួចឈប់ម៉ូតូមុខកាព៉ស់សាំងពាក់អាវភ្លៀង រួចបានឡើងម៉ូតូរៀបនឹងបញ្ចេះ ក៏ស្រាប់តែមានម៉ូតូមួយគ្រឿងម៉ាក គុប៥០ បើកបរទិសដៅពីជើងទៅត្បូង មកបុកតែម្តង។

តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ឡាយហេង បានបញ្ជាក់ថា: នៅថ្ងៃកើតហេតុបានជិះម៉ូតូមកពីទិញបន្លែនៅផ្សារវត្តអង្គ លុះដល់ចំណុចកាព៉ស់សាំងតេលា មានរថយន្តពីរគ្រឿងកំពុងវ៉ាគ្នា ស្រាប់តែម៉ូតូមួយគ្រឿងទៀតបានវ៉ារថយន្តទាំងពីរក្នុងទិសដៅស្របគ្នា ក៏មានរថយន្តដឹកកម្មករពីទិសខាងជើងមកទន្ទឹមនឹងម៉ូតូជនរងគ្រោះដែរ។ ម៉ូតូដែលបានវ៉ារថយន្តពីរគ្រឿងបានគេចពីឡានដឹកកម្មករមកបុកម៉ូតូជនរងគ្រោះតែម្តង។

២.ភស្តុតាងខាងលើ ចម្លើយរបស់ជនរងគ្រោះដែលជាអ្នកបើកបរម៉ូតូម៉ាកគុបC50 រួមទាំងកំណត់ហេតុផ្សេងៗ និងលទ្ធផលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ មានភាពស៊ីសង្វាក់គ្នាកំណត់បានថាគ្រោះថ្នាក់ចរាចរណ៍ខាងលើនេះបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ពន្លក ជាអ្នកមានកំហុស ដែលបានបើកម៉ូតូឡើងផ្លូវជាតិពីឆ្វេង ទៅស្តាំ ដោយគ្មានការប្រុងប្រយ័ត្នទៅបុកម៉ូតូរបស់ជនរងគ្រោះបង្កឲ្យមានគ្រោះថ្នាក់តែម្តង។



Scanned with CamScanner

៣.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] ពន្លក ពីបទ: បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុងមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៤.ឈ្មោះ [redacted] ឡាយហេង បានទទួលសំណងជាប្រាក់មួយចំនួនពីជនជាប់ចោទរួចហើយ ពុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីប្តឹងទាមទារសំណងទៀតឡើយ។ តុលាការពុំមានសមត្ថកិច្ចពិនិត្យសម្រេចបន្ថែមទៀតឡើយ។

៥.វត្ថុចាប់យក: ម៉ូតូ ០២គ្រឿង ម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CX-9611 និងម៉ាកហុងដាC50 ពណ៌ស្លែ ពាក់ផ្លាកលេខ ភ្នំពេញ 1H-5309។ យោងតាមមាត្រា ៧២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក គប្បីសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៧ ជនជាប់ចោទបានឆ្លើយបដិសេធ តែតាមគំនូសចរាចរណ៍ជនជាប់ចោទបានបើកបរបញ្ច្រាស់ទិស សុំឲ្យតុលាការសម្រេចឲ្យផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១ឆ្នាំ ពីបទ: បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៧.មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន: ឆ្លងតាមការដេញដោលនាពេលសវនាការ នៅពេលកើតហេតុជនជាប់ចោទបានចូលចាក់សាំង តែការ៉ាសសាំងអត់បើក ក៏បានជ្រកភ្លៀងហើយចេញមកវិញ ក៏ឈប់ម៉ូតូពាក់អាវភ្លៀង ដោយពុំបានជិះម៉ូតូទៅមុខទេ។ សុំតុលាការឲ្យជនជាប់ចោទរួចខ្លួនពីបទចោទ។ ដោយនៅពេលកើតហេតុជនជាប់ចោទក៏មានរបួស និងខូចខាតម៉ូតូដែរ សុំឲ្យព្យាបាលរបួសរៀងៗខ្លួន។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសឈ្មោះ [redacted] ពន្លក ភេទប្រុស ឆ្នាំកំណើត១៩៩៤ ជនជាតិខ្មែរ មុខរបរកម្មកររោងចក្រ។ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តតាកែវ។ ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ។ ឪពុកឈ្មោះ [redacted] ចន្លន (រ) ម្តាយឈ្មោះ [redacted] មីនា (រ) នៅលីវ ទោសពីមុន គ្មាន។

ដាក់ពន្ធនាគារកំណត់ចំនួន ៦ (ប្រាំមួយ) ខែ។ ទោសនេះត្រូវព្យួរការអនុវត្តធម្មតាទាំងមូល យោងតាមមាត្រា ១០៤-១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ: បើកបរដោយធ្វេសប្រហែសបណ្តាលឲ្យរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិចំបក់ក្អែក ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌ និងទោសដែលមានចែងក្នុងមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២.ប្រគល់:ម៉ូតូមួយគ្រឿងម៉ាក ម៉ាក ហុងដាសេ១២៥ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CX-9611 ទៅឲ្យឈ្មោះ [redacted] ពន្លក វិញ។

៣.ប្រគល់:ម៉ូតូមួយគ្រឿងម៉ាក ហុងដាC50 ពណ៌ស្លែ ពាក់ផ្លាកលេខ ភ្នំពេញ 1H-5309 ទៅឲ្យឈ្មោះ [redacted] ឡាយហេង វិញ។

៤.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ពន្លក និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡាយហេង។



Scanned with CamScanner

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅខេត្តកំពង់ស្ពឺ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]